ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១២៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតលេខាធិការដ្ឋានរបស់ក្រុមបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ មាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រាជបណ្ឌិត្យសភាកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើតលេខាធិការដ្ឋានរបស់ក្រុមបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា សម្រាប់កិច្ចដំណើរការរបស់ក្រុមបណ្ឌិតសភាចារ្យ និងជាសេនាធិការនៃការស្រាវជ្រាវរបស់រាជបណ្ឌិត្យសភាកម្ពុជា។

## ជំពូកទី២

## តួនាទីនិងភារកិច្ចរបស់លេខាធិការដ្ឋាន

**មាត្រា២.-**

លេខាធិការដ្ឋានរបស់ក្រុមបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា មានតួនាទីជាសេនាធិការអចិន្ត្រៃយ៍ សម្រាប់កិច្ចដំណើរការរបស់ក្រុមបណ្ឌិតសភាចារ្យ និងជាយន្តការសម្របសម្រួលក្នុងកិច្ចការស្រាវជ្រាវវិទ្យាសាស្ត្ររវាងក្រុមបណ្ឌិតសភាចារ្យជាមួយនឹងវិទ្យាស្ថាននានារបស់រាជបណ្ឌិត្យសភាកម្ពុជា។

លេខាធិការដ្ឋាននេះ មានភារកិច្ចដូចខាងក្រោម៖

-រៀបចំផែនការការងារនិងសម្របសម្រួលការងារទូទៅជូនក្រុមបណ្ឌិតសភាចារ្យ

-រៀបចំយន្តការដើម្បីជំរុញការងារស្រាវជ្រាវ បកប្រែ បោះពុម្ពផ្សាយ និង ការងារវិទ្យាសាស្ត្រ

-រៀបចំការប្រជុំវិទ្យាសាស្ត្រដើម្បីពិគ្រោះយោបល់អំពីព្រឹត្តិការណ៍សំខាន់ៗរបស់ជាតិនិងអន្តរជាតិ

-រៀបចំសន្និសីទ សិក្ខាសាលា វេទិកាបណ្ឌិតសភា និង វេទិកាវិទ្យាសាស្ត្រនានា

-គ្រប់គ្រងការងាររដ្ឋបាល និង ទំនាក់ទំនងសាធារណៈជូនក្រុមបណ្ឌិតសភាចារ្យ

-សហការ ជំរុញ និងទទួលបន្ទុកការងារបើកផ្តល់ថវិកាឧបត្ថម្ភនិងថវិកាស្រាវជ្រាវ ព្រមទាំងការងារហិរញ្ញវត្ថុជូនក្រុមបណ្ឌិតសភាចារ្យ និងមន្ត្រីក្រោមឱវាទ

-គ្រប់គ្រងការងារសោតទស្សន៍ និងការងារផ្សព្វផ្សាយ

-រៀបចំរបាយការណ៍អំពីសកម្មភាពនិងសមិទ្ធផលការងារ ជូនក្រុមបណ្ឌិតសភាចារ្យ

-រៀបចំរបាយការណ៍របស់ក្រុមបណ្ឌិតសភាចារ្យជូនប្រមុខរាជរដ្ឋាភិបាល

-រៀបចំនិងបណ្តុះបណ្តាលធនធានមនុស្សរបស់លេខាធិការដ្ឋាន ដើម្បីពង្រឹងប្រសិទ្ធភាពនិងបង្កើនសមត្ថភាពនិងគុណភាពការងារ

-ទទួលអនុវត្តការងារផ្សេងៗទៀតដែលក្រុមបណ្ឌិតសភាចារ្យប្រគល់ជូន។

## ជំពូកទី៣

## ការគ្រប់គ្រងនិងកិច្ចដំណើរការ

**មាត្រា៣.-**

លេខាធិការដ្ឋានរបស់ក្រុមបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា ដឹកនាំដោយប្រធាន១(មួយ)រូប អមដោយអនុប្រធានចំនួន២(ពីរ)រូប។ ការបំពេញភារកិច្ចរបស់អនុប្រធានម្នាក់ៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជបណ្ឌិត្យសភាកម្ពុជា តាមសំណើរបស់ប្រធានលេខាធិការដ្ឋាន។

**មាត្រា៤.-**

ប្រធាននិងអនុប្រធានលេខាធិការដ្ឋាន ជាមន្ត្រីនៃរាជបណ្ឌិត្យសភាកម្ពុជា ហើយត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់ក្រុមបណ្ឌិតសភាចារ្យ។

**មាត្រា៥.-**

បទបញ្ជាផ្ទៃក្នុង សម្រាប់កិច្ចដំណើរការរបស់លេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជបណ្ឌិត្យសភាកម្ពុជា។

**មាត្រា៦.-**

មន្ត្រីលេខាធិការដ្ឋាន ជាមន្ត្រីក្របខណ្ឌមុខងារសាធារណៈ ដែលមានចំណេះដឹងនិងសមត្ថភាពខ្ពស់និងមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ។

**មាត្រា៧.-**

មន្ត្រីលេខាធិការដ្ឋាន ដែលជាជំនួយការផ្ទាល់របស់បណ្ឌិតសភាចារ្យម្នាក់ៗ ត្រូវស្ថិតនៅក្រោមខ្សែបណ្តោយផ្ទាល់ជាមួយក្រុមបណ្ឌិតសភាចារ្យ និងស្ថិតនៅក្រោមខ្សែទទឹងនៃការគ្រប់គ្រងរដ្ឋបាលរបស់លេខាធិការដ្ឋាន។

**មាត្រា៨.-**

មន្ត្រីលេខាធិការដ្ឋាន ត្រូវទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្តបន្ថែម តាមការកំណត់របស់រាជរដ្ឋាភិបាល។

**មាត្រា៩.-**

មន្ត្រីលេខាធិការដ្ឋាន ត្រូវទទួលការវាយតម្លៃអំពីគុណភាពនិងប្រសិទ្ធភាពការងារប្រចាំឆ្នាំ។ នីតិវិធីនិងយន្តការនៃការវាយតម្លៃនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជបណ្ឌិត្យសភាកម្ពុជា។

**មាត្រា១០.-**

ការចំណាយសម្រាប់កិច្ចដំណើរការរបស់លេខាធិការដ្ឋាន ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិ ក្នុងគម្រោងថវិកា ក្រោមខ្ទង់ថវិការបស់រាជបណ្ឌិត្យសភាកម្ពុជា នៅក្នុងក្របខណ្ឌថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

លេខាធិការដ្ឋាន មានសិទ្ធិទទួល និងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវធនធាន និងមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀត សម្រាប់កិច្ចដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២**.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានក្រុមបណ្ឌិតសភាចារ្យ ប្រធានរាជបណ្ឌិត្យសភាកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**:

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា១២

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ